# ការសំភាស៍របស់អ៊ំស្រី ឈី មុន

កៈ អ្នកដែលសំភាស៍ សួន សុខលី ខៈ អ្នកដែលត្រូវបានគេសំភាស៍ ឈី មុន

កៈ ជាដំបូងខ្ញុំសូមថ្លែអំណរគុណដល់អ៊ំស្រីដែលអោយខ្ញុំធ្វើការសំភាស៍ពីជីវប្រវិតរបស់អ៊ំ ហើយការសំភាស៍នេះគឺធ្វើឡើងដោយសារសាលាសកលវិទ្យាល័យ BYU ហើយដោយសារតែសកលវិទ្យាល័យនិងចង់ថែរក្សាជីវប្រវិត្តជីដូនជីតារបស់អ៊ំស្រីទុកអោយកូនចៅជំនាន់ក្រោយគាត់មើល។ ហើយបន្ទាប់ពីការសំភាស៍នេះរួចហើយ តើខ្ញុំអាចសូមអ៊ំស្រីអនុញ្ញាតអោយខ្ញុំដាក់ការសំភាស៍មួយនេះទៅលើប្រពន្ធ័វើបផ្សាយមួយដែលមានឈ្មោះថា WWW. Cambodianoralhistories.byu.edu បានដែលទេអ៊ំស្រី?

ខៈ ចាបានតាស អោយខ្ញុំសំភាស៍អីខ្ញុំនិងឆ្លើយនិង។

កៈ ហាហាហា ចាអរគុណអ៊ំ។

ខៈ ចា។

កៈ ហើយការសំភាស៍នេះគឺត្រូវបានធ្វើឡើងដោយនាងខ្ញុំឈ្មោះ សួន សុខលី ហើយធ្វើឡើងនៅថ្ងៃទី៣១ ខែ០១ ហើយឆ្នាំ២០១៨។ ហើយការសំភាស៍នេះធ្វើឡើងនៅក្នុងភូមិបួន អើសង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

កៈ ចឹងសូមអនុញ្ញាតអ៊ំស្រី តើអ៊ំស្រីមានឈ្មោះនិងនាមត្រកូនអីគេដែលអ៊ំ?

ខៈ ខ្ញុំឈ្មោះ ឈី មុន។

កៈ អ៊ំឈ្មោះឈី មុន។

ខៈ ចា។

កៈ ហើយឈ្មោះរបស់អ៊ំនិងដូចជាមួយនិងអតញ្ញាណប័ណ្ណរបស់អ៊ំអត់?

ខៈ ដូចជាមួយគ្នានិងដែលចា ឈី មុន និងដែល។

កៈ ចាហាហាហាមានឈ្មោះពីរោះណាស់អ៊ំ។

ខៈ ចាឈី មុន។

ក៖ ចាហើយចឹងចង់សួរអ៊ំថាតើអ៊ំមានឈ្មោះហៅក្រៅដែលទេអ៊ំ?

ខ៖ អត់មានទេ គឺឈ្មោះ ឈី មុននិងម៉ង គេហៅមុនៗនិង។

ក៖ ចាចឹងអ្នកនៅភូមិនិងគេហៅអ៊ុំថា មុនៗចឹងទៅ?

ខ៖ ចា តែបើនិយាយទៅខ្ញុំនៅខេត្តកំពង់ចាមណា ខ្ញុំមានឈ្មោះ អ៊ន។

ក៖ អ៊ំមានឈ្មោះអ៊ន។

ខ៖ ចាពេលឪពុកម្តាយខ្ញុំនៅស្រុកកំពង់ចាមនិងគេហៅខ្ញុំឈ្មោះអ៊ន
តែពេលខ្ញុំមានគ្រួសារមក មកនៅស្រុកល្វាអែម ភូមិបឹងគ្រុម ស្រុកល្វាអែម
ខេត្តកណ្តាលណា។

ក៖ ចា។

ខ៖ តែពេលនិងខ្ញុំប្រែឈ្មោះថា ឈ្មោះមុន តែឈ្មោះពិតខ្ញុំឈ្មោះអ៊ន។

ក៖ ចាចឹងមានន័យថាអ៊ំប្រែឈ្មោះនិងដាក់មុននិងនៅក្នុងអតញ្ញាណប័ណ្ណនិងឈ្មោះមុន។

ខ៖ ចាឈ្មោះមុន អត្តញ្ញាណប័ណ្ណខ្ញុំឈ្មោះមុន គឺឈី មុននិងម៉ង។

ក៖ ចាហាហាហា។ អរគុណអ៊ំ។

ខ៖ ចា។

ក៖ ចាហើយចឹងខ្ញុំចង់សួរអ៊ំស្រីទៀតថា អាឡូវនិងអ៊ំមានអាយុប៉ុន្មានហើយ?

ខ៖ អាយុប្រជន្មនេះ ហុកសិបពីរឆ្នាំ។

ក៖ ចាហើយអ៊ំកើតនៅឆ្នាំណាខែណា?

ខ៖ អរខ្ញុំភ្លេចភ្លាំងអស់ហើយ អាលុតម៉ង ចឹងបានថាអោយនិយាយចឹងអាលុតម៉ង
តែបើថាមើលអោយមើលអត្តញ្ញាណប័នហើយនិងសួរខ្ញុំគឺខ្ញុំឆ្លើយអត់ត្រូវទេណាក្មួយ។

ក៖ ចា។

ខ៖ ខ្ញុំឆ្លើយអត់បានទេ
តែបើថាមើលបញ្ជីជាតិអីអានិងអាចឆ្លើយបានព្រោះយើងវាមិនបានចាំបានអី។

កៈ ចាចុះអ៊ំទុកអត្តញ្ញានប័ណអីនៅណាអ៊ំ? ពីបាករកទេ?

ខៈ នេះមានតាស អត្តញ្ញានប័ណខ្ញុំនិងមានតាស។

កៈ ចា។

ខៈ បើថាអោយខ្ញុំឆ្លើយគឺអត់មានការចង់ចាំទេ។

កៈ ចាចឹងខ្ញុំអាចសុំការអនុញ្ញាតអ៊ំ រំខានអ៊ំតិចយកអត្តញ្ញានប័ណមក ហើយយើងអាចមើលបានទេអ៊ំ?

ខៈ ចាបានតាស បាន។

កៈ ចាអរគុណអ៊ំ។ ចឹងខ្ញុំមើលទៅតាមអត្តញ្ញានប័ណរបស់អ៊ំណា អ៊ំអើកើតនៅថ្ងៃទីមួយម្ភៃប្រាំមួយ ខែប្រាំមួយ ឆ្នាំមួយពាន់ប្រាំបួនរយហារសិបប្រាំពីរ ត្រូវទេអ៊ំ?

ខៈ ចា។

កៈ ហើយអ៊ំមានស្រុកកំណើតនៅទីណាដែលអ៊ំ?

ខៈ ស្រុកកំណើតខ្ញុំនៅ ឃុំមហាសៀក ស្រុកកោះសទិន ខេត្តកំពង់ចាម។

កៈ ចានៅភូមិអីគេដែលអ៊ំ?

ខៈ នៅភូមិមហាសៀក។

កៈ ភូមិមហាសៀក។

ខៈ ចា។

កៈ ចឹងមានន័យថាស្រុកកំណើតរបស់អ៊ំនៅកំពង់ចាម ហើយអាឡូវអ៊ំផ្លាស់ទីលំនៅមកនៅភ្នំពេញវិញ?

ខៈ ផ្លាស់ទីលំនៅពេលខ្ញុំកាលមានប្តីមានគ្រួសារមកនៅខាងប្តីនៅខេត្តល្វាអែម។

គៈ មានណាម៉ែនៅខេត្តកណ្តាល។

ខៈ អរនៅខេត្តកណ្តាល នៅភូមិបឹងគ្រុម ស្រុកល្វាអែម ខេត្តកណ្តាលនិង។

កៈ ចាហើយបន្ទាប់មកបានមកនៅបឹងត្របែកនេះ?

ខៈ ហើយពេលនិងវាអត់ពេក ចេញដំណើមក មករកស៊ិនៅទីនិង។
ចាមករកស៊ិនៅនិងជាប់ជិតដប់ឆ្នាំហើយណា។

គៈ អានិងនិយាយកាត់ហើយណា។

កៈ ចា។

ខៈ មករកស៊ិនៅនិង
បើតាមនិយាយចេញមកយូរហើយមករកស៊ីតាំងពីនៅសប្បុកចាបមិនទាន់ឆេះ
ពេលគេបញ្ជេះហើយ យើងរស់នៅជាមួយថៅកែនិងដែលយើងស្វែងរកស៊ិអីចឹងណា
ថៅកែគាត់ចេះតែជួយយើងទៅ យើងនេះចេះតែមកតាមគាត់ទៅ
គាត់ចេះតែជួយយើងអោយមករស់នៅជាមួយគាត់ទៅ នៅបឹងត្របែកនិងមកទៀតទៅ។

កៈ ចាចឹងអ៊ំខ្ញុំចង់សួរអ៊ំទៀតថាឆ្នាំខ្មែរណា តើអ៊ំមានឆ្នាំអីគេដែល? ជូត រការអីនិងអ៊ំ?

ខៈ អើឆ្នាំនិងមែន?

កៈ ចាដូចជាអ៊ំកើតនៅឆ្នាំរការ ឆ្នាំថោះអីនិង។

ខៈ ខ្ញុំកើតនៅឆ្នាំរការ។

កៈ អរអ៊ំឆ្នាំរការដូចខ្ញុំដែល។

ខៈ ចាហាហាហា។

កៈ ហាហាហា រសេវាយណាស់អ៊ំ។

គៈ ឆ្នាំអីឆ្នាំរការនិងឭកែកកាយចង់ងាប់និង។

ខៈ អើកាយអីកាយមកអោយកូនស៊ីបានឆ្អែតនិង ហាហាហា។

កៈ ហាហាហា ខ្ញុំមានអារមណ៍ថាជួបអ៊ំ សំភាស៍អ៊ំសប្បាយមែនទែន។

ខៈ ចារួចមេច គេសំភាស៍ថាមេចទៅទៀតកូន?

កៈ ចាហើយខ្ញុំចង់សួរអ៊ំស្រីថាអ៊ំស្រីមានបងប្អូនជំនួនប៉ុនន្មាននាក់ដែល?

ខ៖ បងប្អូនអំមានប្រាំពីរនាក់។

ក៖ ចាហើយអំកូនទីប៉ុន្មាន?

ខ៖ កូនទីមួយ។

ក៖ ចាចឹងអាចសុំខានអំអាចរៀបរាប់ឈ្មោះពីកូនទីមួយរហូតដល់ទីប្រាំពីរនិងបានទេ?

ខ៖ ចាចាំមើលណាឈ្មោះខ្ញុំថាពីឈ្មោះនៅទីនោះណា ឈ្មោះឆេងអ៊ន ឆេងអ៊នហើយ អាឈាន ឈានហើយ អាធឿន ធឿនហើយអើ ឆេងង៉ន ហើយឆេងងឹម ឆេងងឹមហើយ ចាន់ណាបានតែប្រាំនាក់និង។

ក៖ ប្រាំមួយនាក់ហើយអំ នៅម្នាក់ទៀត។

ខ៖ ម្នាក់ទៀតបាត់បង់ហើយមិនបាច់និយាយទេ។

ក៖ ចាចឹងពួកគាត់ស្លាប់អស់ហើយមែនទេអំ?

ខ៖ ចាស្លាប់ហើយយើងមិនបាច់នេះទេយើង។

ក៖ តែអំអាចប្រាប់ឈ្មោះគាត់ស្លាប់បានទេ?

ខ៖ ស្លាប់អើឈ្មោះអើ ឆេងអៀង។

ក៖ ឈ្មោះឆេងអៀង គាត់ពៅគេនុះអំ?

ខ៖ ចាពៅគេ។

ក៖ ចាហើយ។

ខ៖ អរនៅមួយទៀតឆេងងឹម អើមានទេ
ហើយចាន់ណាមានមួយទៀតអើភ្លេចបែកបងប្អូនយូរហើយណាក្មួយអើយ
ខ្ញុំនៅបានតែត្រឹមនិងណាមិនដែលបានទៅលេងទេ ព្រោះវាអត់ដើរកើតនិងណា
ហើយខ្ញុំវាជាប់ការវេទនានិងលំបាកខ្លាំង
សព្វថ្ងៃរស់នៅទីនេះចិញ្ចឹមចៅកំព្រាប្រាំនាក់ទៀតណាស់។

ក៖ អរចា។

ខ៖
និងហើយចិញ្ចឹមចៅកំព្រាប្រាំនាក់និងកូនគេបែកគ្រួសារគេទៅនៅឯណាឯនីអស់ហើយណាស់ នៅតែខ្លួនឯងហើយនិងចៅកំព្រាប្រាំនាក់និង សព្វថ្ងៃទៅរៀននៅអង្គារ ទៅរៀនអង្គារហើយជូនណាហូមបាយនៅអង្គារទៅ ជូនណាជីដូនដាំទៅ ដាំព្រឹកទុកស៊ីល្ងាចទៅ។ និងហើយវាពិបាក។

ក៖ ចាអំ។ ចឹងអើខ្ញុំចង់សួរំទៀតថាតើអំអើមានចាំសាច់រឿងអំពីបងប្អូនរបស់អំទេអំ? កាលពីក្មេងធ្លាប់ធ្វើអីគេខ្លះជាមួយគ្នា?

ខ៖ ពីប្រវិត្តបងប្អូន?

ក៖ ចា។

ខ៖ កាលនៅតូចៗនិងមានតែខ្ញុំនិងបងគេ ឃើញប្អូនគឺនៅតែរៀនសូត្រ ធ្វើការឪពុកខ្ញុំមានការងារធ្វើស្រែចំការ ឪពុកខ្ញុំឡើងត្នោតចឹងណា ឡើងត្នោតទៅ ទៅរកអុសរកអីសំរាប់យកមកដុតភ្លើងស្ករអោយឪពុកម្ដាយអីចឹងទៅ តែខ្ញុំបងគេឈានជំហានទៅមុខ ខ្ញុំទៅទទួលបន្លែអីយកទៅលក់ដល់ផ្សារចង្ហៃស្រុកកំពង់ចាមនិងណា ផ្សារចង្ហៃរមានថ្ងៃណាមួយនុះខ្ញុំយកអំពិលទុំទៅលក់ដល់ស្រុកយួនទៀត ទៅជាមួយគេចាស់ម្ដាយធ្វើតាមគេទៅ និយាយពីប្រវិត្តចាស់និងកំសត់ណា។

ក៖ ហាហាហាចាអំ។ ហើយអើខ្ញុំចង់សួរអំទៀតថានៅពេលណា អើនៅពេលពីក្មេងនិងតើអំចូលចិត្តលេងអីខ្លះហើយធ្វើអីខ្លះជាមួយពួកគាត់ដែល?

ខ៖ មានចូលចិត្តលេងអីទេ មានតែចូលចិត្តនាំបងប្អូន អើកាលនៅពីតូចនិងមិនដឹងថាលេងស្អីទេ លេងនេះអីធ្វើអីកំប៉េកប៉ុក បើថានិយាយពីរឿងក្មេងវាមិនទាន់ដឹងវ៉ៃអីទេណាក្មួយណា។

ក៖ ចាអំ។

ខ៖ គឺចូលចិត្តលេងលក់ដូដំប៉េកកំប៉ុកនិង។

ក៖ ចាអានិងគេលេងបីលុកបីល៍។

ខ៖ ចានិងហើយ លែងតែអាចឹងបីលុកបីល៍ចឹង មានអីមានពីបាកអីចឹងចា។ គ្មានអីទេ ហើយម្ដាយឪពុកក្រ ឪពុកខ្ញុំពីមុននៅស៊ីឈ្នួលប៉ះកង់ប៉ះអីអោយគេចឹងណា ម្ដាយខ្ញុំដើរស៊ីឈ្នួលប៉ះសណ្ដែកប៉ះអីអោយគេចឹងណាស់ ដល់តែម៉ែទៅប៉ះនិងកូនក៏នាំគ្នាទៅតាមទៅក៏ជួយប៉ះតាមពីក្រោយតាមអីគេនិងចឹងទៅ ចឹងឯងជីវិតជីវះនិង។

ក៖ ហើយអាឡូវខ្ញុំចង់សួរអំស្រីទៀតថា តើអាឡូវពួកគាត់ធំៗនិង តើពួកគាត់នៅកន្លែងណាដែលអំ?

ខ៖ អរនៅនិងចឹង វានៅស្រុកណាចឹងណាអូន វានិងឯស្រុកនិងទេ។

ក៖ នៅស្រុកនិងនៅឯណាដែលអំ?

ខ៖ នៅឯស្រុកនិងគឺនៅកំពង់ចាមនិងឯង តែឪពុកម្ដាយនិងស្លាប់អស់ហើយ។

ក៖ ចា។

ខ៖ តែនៅតែបងប្អូនតែប៉ុន្មាននាក់ដែលកំពុងតែរស់នៅទីនិង កុំពង់តែវេទនាតោកយ៉ាកនៅនិងកំពង់ចាំនិងឯង តែខ្ញុំបងគេគឺបែកចាប់តាំងពីខ្ញុំមកមានគ្រួសារនៅទីនេះមកម្លេះនិងហើយ ប៉ុន្តែពីបាកណាស់បែកបាកគ្នាអូនហើយ។

ក៖ ចឹងខ្ញុំចង់សួរអំទៀតថា តើឪពុកម្ដាយរបស់អំណាស់ពួកគាត់មានឈ្មោះអីគេខ្លះដែលអំ?

ខ៖ អើឈ្មោះមើលនាមត្រកូលគាត់ ខ្ញុំស្គាល់តែឈ្មោះគាត់ទេ ឪពុកគាត់ឈ្មោះថា តាឈុំ ឈឹម រួចហើយម្ដាយឯនុះឈ្មោះថា អ៊ុយ ស៊ឹម។

ក៖ អ៊ុយ ស៊ឹម។

ខ៖ ចា។

ក៖ ហើយពួកគាត់អាឡូវមានអាយុប៉ុន្មានដែលអំ?

ខ៖ អើគាត់ម្ដាយស្លាប់ហើយ ឪពុកខ្ញុំមានអាយុប៉ុន្មានទេ អាយុខ្ទង់ជិតប៉ែតសិបហើយ។

ក៖ ចាចុះគាត់នៅរស់ឬក៏ស្លាប់ដែលអំ?

ខ៖ គាត់នៅរស់ចា ឪពុកនិងនៅរស់ ម្ដាយស្លាប់។

ក៖ ចាចុះឪពុកអំគាត់រស់នៅសព្វថ្ងៃនិងគាត់រស់នៅឯណាដែលអំ?

ខ៖ គាត់រស់នៅឃុំមហារសៀក។

ក៖ ចាហើយអើម្ដាយរបស់អំគាត់ស្លាប់នៅឆ្នាំណាខែណាដែលអំ?

ខ៖ អួយកាលឆ្នាំគាត់ស្លាប់និងមិនដឹងទេកូនអើយ ព្រោះពេលនិងនៅបែក ពីដែលគាត់ស្លាប់និងគេមកតាមអោយទៅម្ដាយនិងខ្ញុំមិនដឹងថ្ងៃណាទីណាទេ ព្រោះខ្ញុំវង្វង់វេងតែម្ដង។

ក៖ ចាចឹងអំមានចាំថាខាងអំប្រុសអំស្រីខាងអើឪពុកម្ដាយរបស់អំនិង តើគាត់កើតនៅឆ្នាំណាខែណាដែលអំ?

ខ៖ អើអត់ដឹងផង។

ក៖ ចាចឹងគាត់អាយុឆ្នាំអីគេដែលអំ ដូចជាឆ្នាំជូត ឆ្លូវអីនិង?

ខ៖ អើឪពុកឆ្នាំខាល។

ក៖ ចាចុះម្ដាយ?

ខ៖ ម្ដាយឆ្នាំថោះ។

ក៖ ហើយអើខ្ញុំចង់សួរអំទៀតថា តើអំមានចង់ចាំអំពីសាច់រឿងដូចជាពេលដែលពួកគាត់នៅពីក្មេងណា តើពួកគាត់មានធ្លាប់ប្រាប់អំអត់?

ខ៖ អើមានប្រវត្តពីក្មេង។

ក៖ ចា។

ខ៖ បើពីក្មេងថាចេះ អានិងចូលវកថា វកពីក្មេងនិងមើលអ្នកគ្រូនិយាយអោយខ្ញុំស្ដាប់តិចសិនមើលថាពីក្មេងនិងវាមេចខ្លះ?

ក៖ ដូចជាឪពុកម្ដាយរបស់អំនិងនៅពីក្មេង ដូចជាកាលពេលដែលអំនៅក្មេងនិង តើឪពុកម្ដាយរបស់អំធ្លាប់និយាយរឿងអីខ្លះអំពីប្រវិត្តរបស់ពួកគាត់អោយអំស្ដាប់?

ខ៖ បើនិយាយពីប្រវិត្តដូចជា មានប្រវត្តិថាម៉ែនិងខំ
ចាំមើលម្ដាយគាត់និយាយថាទំរាំតែបានគ្នានិងណា
កូនអើម៉ែទំរាំតែបានប៉ាឯងនិងណាកំសត់ណាស់ពីដើមភូមិចុងភូមិ
ដល់តែពេលនេះម៉ែឪគេមានគេមកយកម៉ែចឹងណា គេមកស្ដាត់លើស្ដាត់ក្រោម
ទំរាំតែបានស្រលាញ់គ្នាពួកគាត់អត់អោយចាស់ទុំអីដឹងចឹងណា
ព្រាត់គ្នានាំគ្នាទីនៅជប់ស្វូង នាំគ្នាស៊ីបាយប្អូម
គាត់និយាយប្រាប់ខ្ញុំថាចឹងទំរាំតែបានគ្នាណាកូន
និងបានស្រាលាញគ្នាដោយសារតែពង្រាត់គ្នាទៅ
រួចឪពុកខ្ញុំក៏ធ្វើជាងកង់នៅជប់ស្វូងនិងទៅ គឺនៅស្រុកជប់ស្វូង នៅឯទំពាំងអាសីនុះ
ហើយទំរាំតែរកបានការងារធ្វើ សុំគេសុំផ្ទះគេនៅហើយធ្វើនៅនិងសំយាបផ្ទះគេ
ហើយបានអីតិចតួចមករួចម្ដាយខ្ញុំក៏ទំងន់ខ្ញុំ
រួចគាត់ថាខ្ញុំនិងចង្រៃររកអីហូមមិនបានទៅស៊ីតែបាយប្អូម ហាហាហា។

ក៖ ចាអ៊ំ។

ខ៖ នាំគ្នាស៊ីបាយប្អូម ហើយពីនាក់ប្ដីប្រពន្ធនិងបានចាប់ដៃគ្នា
រួចម្ដាយឪពុកពួកគាត់និងដឹងប្រវិត្តថាកូនស្រលាញ់គ្នាកំសត់រួចពួកគាត់និងក៏ហៅកូនទាំង
ពីនិងអោយទៅផ្ទះវិញទៅ យកទៅនែនាំរៀបចំអោយហើយអោយស្រលាញ់គ្នាចឹងទៅណា
និងប្រវិត្តពួកគាត់ពីបាកវេទនាចឹងដែល។
អានិងចឹងរួចពីបាកម្ដាយដើរស៊ីឈ្នួលប៉ះត្រកូនអោយគេ
ហើយឪពុកខ្ញុំនៅប៉ះកង់ប៉ះអីអោយគេចឹងណាព្រឹកបានខ្វះល្ងាច
បានល្ងាចខ្វះព្រឹកចឹងទៅ។

ក៖ ចាអ៊ំ។

ខ៖ ចាអានិងនិយាយពីប្រវិត្តគាត់។

ក៖ ចាអរគុណអ៊ំស្រី ហើយចឹងខ្ញុំចង់សួរអ៊ំស្រីទៀតថា
តើឪពុករបស់អ៊ំធ្លាប់ធ្វើអ្វីខ្លះសំរាប់មុខរបស់ចិញ្ចឹមជីវិតរបស់គាត់ដែលអ៊ំ?

ខ៖ ជីវិតរបស់គាត់និងពីមុនគាត់ឡើងត្នោត
ដល់តែគាត់ពិបាកពេកទៅបានជាគាត់រត់ទៅនៅឯនេះនិងណា
ទៅធ្វើប៉ះកង់ប៉ះអីអោយគេចឹងទៅ និងទៅស៊ីឈ្នួលគេនិង

និងហើយប្រវិត្តគាត់មានតែប៉ុននិង ហើយធ្វើចំការ ដាំសណ្តែកអីតិចតួច ជួលដីដាំចំការគេណា ដាំសណ្តែកដីរអីចឹងទៅ។

ក៖ ចាអ៊ំ ហើយខ្ញុំចង់សួរអ៊ំទៀតថា តើឪពុកម្តាយរបស់អ៊ំនិងពួកគាត់គឺជាមនុស្សបែបណាដែលសំរាប់អ៊ំណា?

ខ៖ អីគេ?

ក៖ ដូចជាចង់សួរថាគាត់ស្លូត គាត់ល្អឬក៏យ៉ាងណាដែលសំរាប់អ៊ំ?

ខ៖ អរគាត់ស្លូតណាស់ គាត់ចិត្តល្អ គាត់ចេះនែនាំកូន គាត់មានព្រំវិហារធម៌ចំពោះកូន នែនាំថាកូនអើយជាតិនេះណាម្តាយឪពុកក្រ កូនមកកូនប្រឹងរៀនសូត្រអោយចេះដឹង ចូលធ្វើការអ្វើៗមកដល់សព្វថ្ងៃនេះគេរកតែអ្នកចេះដឹងទេ ដល់យើងធ្វើការអ្វើៗ យើងចេះដឹងអ្វីមួយទៅយើងរកអាចចេះតែបានចូលហើយ បើយើងល្ងុងខ្លៅយើតទៅណាក៏មិនសូវបានសំរេចដែល និងឪពុកម្តាយខ្ញុំគាត់ចេះតែប្រដែលប្រដៅខ្ញុំចឹងណា។ គាត់ចេះតែនែនាំអោយកូនបានល្អចឹង តែប្រវិត្តកំសត់ណាស់។

ក៖ ចាអ៊ំ។

ខ៖ រួចមកដល់ខ្ញុំហើយដល់មកបានប្តីនេះនិងរឹតតែកំសត់ទៅទៀត។

ក៖ ចាចឹងខ្ញុំចង់សួអ៊ំស្រីទៀតថា តើម្តាយរបស់អ៊ំ តើគាត់ធ្វើអ្វីខ្លះសំរាប់ចិញ្ចឹមជីវិត និងជាមនស្សបែកណាដែលសំរាប់អ៊ំ?

ខ៖ អើគាត់គ្មានធ្វើអីទេ ខ្ញុំដឹងថាគាត់នៅពេលដែលខ្ញុំដឹងក្តីនិងគឺម្តាយខ្ញុំនិងគាត់ឈឺរហូត ហើយឪពុកខ្ញុំនិងគាត់រកចិញ្ចឹមនិង ម្តាយខ្ញុំដល់ពេលណាបំពង់កគាត់ជាស្រួលទៅ គាត់ទៅស៊ីឈ្នួលគេប៉ះសណ្តែកប៉ះអីអោយគេនិង ហើយនិងរៀបថ្នាំការតាបអោយគេនិងព្រោះនៅកំពង់ចាមគេច្រើនតែរៀបថ្នាំការតាប ហើយដើរស៊ីឈ្នួលគេធ្វើនូវអ្វីៗទាំងអស់និងទៅ។

ក៖ ចា។

ខ៖ ហើយបានចឹងយកមកចិញ្ចឹមកូននិង ពេលបានលុយមកយកអោយកូន កូនហាកូនឯយកលុយទៅទិញអង្ករមួយគីឡូមកដាំបាយ

ហើយម្ហូបចាំមើលពុកឯងមកល្ងាចឬក៏អីយកលុយនិងទិញអង្ករមកអោយតែបានដាំបាយស៊ីសិនទៅ និងនាំកូននាំចៅ។

កៈ ចាហើយគាត់ជាមនុស្សបែបណាសំរាប់អំដែល ម្តាយអំ?

ខៈ ម៉ែខ្ញុំគឺគាត់ល្អណាស់
គាត់អប់រំកូនទោះបីយ៉ាងមេចក៏ដោយក៏គាត់នៅតែរកលុយចិញ្ចឹមកូន
ទោះបីជាគាត់អត់លុយអត់កាក់ក៏ដោយក៏គាត់ទៅជឿគេដើម្បីយកលុយមកចិញ្ចឹមកូនណាអានិងចឹងគាត់មិនអោយថាកូនពីបាកវេទនាតរទៅមុខដូចគាត់ទៀតទេ
គាត់អោយកូនប្រឹងប្រែង។

កៈ ចាចឹងខ្ញុំអរគុណអំច្រើន
ហើយចឹងអំកាលនៅពីក្មេងអំធ្លាប់ចង់ចាំសាច់រឿងអ្វីខ្លះអំពីឪពុកម្តាយអំណាស់?

ខៈ ដូចជាគ្នាចង់ចាំអីទេកូន ព្រោះបែកគ្នាយូរហើយ បែកតាំងពីខ្ញុំនៅជំទង់មកម្លេះ។

កៈ ចា។

ខៈ បែកមក មកនៅអាពពតជំលៀស់មកណា បែកខ្វែកគ្នាខ្ញុំមកនៅស្រុកល្វាអែមនិងណា
ហើយធ្វើការធីនិងគេទៅ ហើយបានជួបប្តីខ្ញុំ
គេស្រលាញ់អាណិតខ្ញុំនិងក៏គេយកធ្វើជាអនាគតទៅ ខ្ញុំបែកពីម៉ែឪយូហើយ។

កៈ ចាចឹងអំបែកពួកគាត់តាំងពីសម័យពពត?

ខៈ ចាបែកតាំងនៅសម័យពពតនិងមករហូត
ដល់តែដាច់ហើយគេថានុះម៉ែឪនៅរស់បានទៅលេងពួកគាត់តែបីរដងគត់
ពេលម្តាយខ្ញុំគាត់រៀបស្លាប់និងគេមកតាមខ្ញុំនៅល្វាអែមនិង
ហើយបានទៅតែម្តងនិងព្រោះម្តាយស្លាប់ហើយ។

កៈ ចុះសម័យពពតនិងអំមានបានឆ្លងកាត់អីខ្លះ
ដូចជាឧបសគ្គអីខ្លះអំអាចរៀបរាប់ប្រាប់ខ្ញុំបន្តិចតើបានទេអំ?

ខៈ  សម័យពពតគឺឆ្លងកាត់និងកង់ទ័ព្វនិងកង់ចល័តនិងឯដែលពិបាកនោះ។

កៈ ចា។

ខ៖ គឺវេទនាសព្វបែបសព្វយ៉ាង យើងនិងត្រូវធ្វើការអោយពួកវាចឹងទៅណា ទៅធ្វើការទាំងយប់ទាំងថ្ងៃទៅជីកប្រឡាយអីនិង វេទនាបំផុតគឺបវេទនាណាស់។

ក៖ ចាហើយអ៊ំអាចរៀបរាប់បន្ថែមទៀតថាមេចខ្លះ?

ខ៖ អើវាចេះតែប្រើយើងអត់មានពេលសំរាកពេលនេះទេណា ពេលដែលហើយដល់ម៉ោងកណ្ដឹងម៉ង់អីចឹងនាំគ្នាមកស៊ីតែបបរម្នាក់មួយវែកអីនិងចឹងទៅ ដល់ពេលរួចទៅយើងត្រូវទៅរៀបចំអ្វីៗដូចថាការងារយើងដូចថាមានខោរអៅអីត្រូវទៅបោកគក់មួយកំផ្លេរពីអីចឹងទៅរួចដាក់ហាលទៅ ហើយទៅធ្វើការទៀត ល្ងាចមកវិញហើយយប់ធ្វើកាងារសង្គមនិយមទៀត គ្មានបានសំរាកទេជំនាន់ពពតគឺវេទនាបំផុត។

ក៖ ចាចុះកាលនិងអ៊ំមានអាយុប៉ុន្មានដែលអ៊ំ?

ខ៖ អាយុនេះហើយ កាលនិងគឺដប់ប្រាំបីរ ឬក៏ដប់ប្រាំបួនឆ្នាំ និងហើយអាយុប៉ុននិង ពេលដែលខ្ញុំបានមករស់នៅដល់ពេលនេះរួចទៅមានគេអ្នកធ្វើការនិងស្រលាញ់ខ្ញុំណាស់ និងហើយគេហៅគាត់ថាឆ្លប់ៗនិង ដល់ពេលហើយគេឃើញខ្ញុំនិងគេអាណិតស្រលាញ់ខ្ញុំនិងគេក៏ប្រាប់អង្គារគេនិង រួចហើយគេក៏យកទៅរៀបការអោយទៅ។

ក៖ ចា។

ខ៖ ចាគេយកទៅរៀបការអោយខ្ញុំទៅ គេអាណិតស្រលាញ់យើងណា។

ក៖ ចាចឹងខ្ញុំចង់សួរអ៊ំទៀតថាតើជីដូនជីតាខាងម្ដាយអ៊ុំណា តើពួកគាត់មានឈ្មោះអីគេដែលអ៊ំ?

ខ៖ ចាសូម្ដងទៀត?

ក៖ អើជីដូនជិតា យាយតាអំណាខាងម្ដាយនិងមានឈ្មោះអីគេដែល?

ខ៖ ឈ្មោះអឺ អុយ ផឹង។

ក៖ ឈ្មោះអុយ ផឹង?

ខ៖ ចាអុយផឹង រួចខាងឪពុក ឈុំ ជី។

កៈ ចាអុំតែខ្ញុំចង់សួរទាំងយាយទាំងតានិងមានឈ្មោះអី?

ខៈ អើប្រពន្ធតានិង អើខ្ញុំមិនស្គាល់ប្រវិត្តេជីដូនទេ ស្គាល់តែ តាឈុំ យាយជឺ តាអុយទេ។

កៈ ចា។

ខៈ ប៉ុនន្តែឪពុកគាត់តទៅទៀតខ្ញុំអត់បានស្គាល់ទេ។

កៈ ចាចុះអុំមានចាំថាពួកគាត់កើតនៅឆ្នាំណា ខែណាទេអុំ?

ខៈ អើអត់ចាំសោះហើយ អារឿងនិងអុំល្ងង់ខ្លៅតែម្ដង ល្ងង់នោះគឺថាល្ងង់ម៉ង។

កៈ ចាមិនអីទេអុំ?

ខៈ ល្ងង់តែម្ដងគឺមិនចេះ។

កៈ ចាចុះអុំកាលនៅពីតូចៗនិងអុំធ្លាប់រស់នៅទាន់ជំនាន់យាយតាអុំដែលទេអុំ?

ខៈ អើនៅ នៅទាន់តាសយាយតាខ្ញុំ។

កៈ ចាហើយអុំរស់នៅជាមួយពួកគាត់និងអុំធ្វើអីខ្លះចឹងណា?

ខៈ អើនៅជាមួយគាត់និង តែកាលនិងខ្ញុំនៅជាមួយឪពុកម្ដាយខ្ញុំទេណាកាលនិង
តែជីដូនជីតាខ្ញុំនិងរស់នៅផ្ទះដោយខ្លួនទេណា
តែឪពុកខ្ញុំគាត់ប្រើខ្ញុំម្ដងៗអោយទៅផ្ទះជីដូនជីតាខ្ញុំនិងដូចថាគាត់ធ្វើចំការដាំអំពៅ
ដាំអីផ្សេងៗហើយនិងអើ អើយាយខ្ញុំនិងគាត់ត្បាញក្រមារ។
ចឹងពួកគាត់ចាស់ពីដើមគាត់ធ្វើចឹង និងហើយ។

កៈ ចាហើយចុះអុំចេះត្បាញក្រមារទេអុំ?

ខៈ ខ្ញុំចេះដែលតាស ចេះត្បាញ។

កៈ ហាហាហា ចឹងអុំចេះត្បាញក្រមារដែល។

ខៈ ចាប៉ុនន្តែម៉ែខ្ញុំគាត់លើកអោយមួយគឺនិងគឺត្បាញកូនក្រមារទេ
គាត់មិនអោយត្បាញក្រមារធំៗទេព្រោះខ្លាចខូចក្រមារ។ កាលនិងខ្ញុំត្បាញកូនក្រមារតូចៗ
កីនិងណា។

កៈ ចាអ៎ំ?

ខៈ និងហើយ។

កៈ ចឹងអគុណអ៎ំហើយខ្ញុំចង់សួរអ៎ំទៀតថា
តើបងប្អូនក្រុមគ្រួសាររបស់អ៎ំនិងតើពួកគាត់បានទៅរស់នៅខេត្តណាខ្លះ
ពេលពួកគាត់រៀបការហើយណា?

ខៈ អ្នកដែលរៀបការហើយអើ ចង់និយាយពីបងប្អូនអី?

កៈ ចា។

ខៈ អើនៅមូលគ្នាជុំគ្នានៅនិងម៉ង។

កៈ អរនៅជុំគ្នាណាអ៊ុំ?

ខៈ ចានៅមូលគ្នានៅឃុំមហារសៀកនិងម៉ង ស្រុកកោះសុទិននិងតែម្តង
តែបែកគេតែខ្ញុំមួយទេ។ គឺបែកតាំងពីនេះឯនុះគឺតាំងពីយើងនៅជំនាន់អាពពតនិងហើយ
រួចក៏មកនៅចឹង ចេញពីល្វាអែមនិងយូហើយចា។

កៈ ចាហើយអើខ្ញុំចង់សួរអ៎ំទៀតថា
តើអ៎ំមានសាច់ញាត្តិដ៏ទៃទៀតដែលរស់នៅប្រទេសក្រៅទេអ៎ំ?

ខៈ អត់ អត់មានទេ។

កៈ អត់មានសោះម៉ងអីអ៎ំ?

ខៈ ចាគឺអត់មានសោះ។

កៈ ចឹងពួកគាត់នៅស្រុកខ្មែរទាំងអស់អីអ៎ំ?

ខៈ និងហើយនៅស្រុកខ្មែរនិងទាំងអស់ អត់មាននៅប្រទេសក្រៅទេ។

កៈ ចាហើយអើខ្ញុំចង់សួរអ៎ំទៀតថា តើស្វាមីរបស់អ៎ំមានឈ្មោះអីគេដែល?

ខៈ ប្តីខ្ញុំមានឈ្មោះថា ចាន់អរ។

កៈ គាត់ឈ្មោះចាន់អរ។

ខ៖ ចា។

ក៖ ហើយអ៊ំបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅឆ្នាំណា ខែណាដែលទៅអ៊ំ?

ខ៖ អរយូរណាស់ហើយ មិនដឹងថាឆ្នាំប៉ុន្មានទេ។

ក៖ ចា។

ខ៖ ហើយបើគិតទៅភ្លេចអស់ហើយ យូរណាស់តាំពីយើងបែកមក។

ក៖ ចាចុះពេលនិងអ៊ំប្រហែលជាមានអាយុយប៉ុន្មាន?

ខ៖ កាលនិងអាយុខ្ញុំប្រហែលប៉ុន្មានដប់ឆ្នាំជាងនិង ប្រហែលដប់ប្រាំពី ដប់ប្រាំបីឆ្នាំនិង។

ក៖
ចាចឹងមានន៏យថាអ៊ំអាយុដប់ប្រាំពីរដប់ប្រាំបីរឆ្នាំនិងអ៊ំបានជួបជាមួយអ៊ំប្រុសហើយរៀបការតែម្តង?

ខ៖ ចាការ។

ក៖ ចាហើយការរៀបការនិងឪពុកម្តាយរបស់អ៊ំជាអ្នករៀបចំអោយឬក៏
អ៊ំពេញចិត្តដោយខ្លួនឯង?

ខ៖ អត់ទេ អត់ទេគេជាអ្នករៀបអោយទេ។

ក៖ ចាខាងឪពុកម្តាយខាងប្រុស?

ខ៖ ឪពុកម្តាយនេះគេរៀបអោយទេ មិនមែនម៉ែឪខ្ញុំទេរៀបអោយទេ ចា។

ក៖ ហើយអើ ខ្ញុំសូមរំខានអ៊ំមួយទៀតថា
តើអ៊ំប្រុសអរតើអ៊ំស្រីបង្កាប់ថ្លៃជំនូនពីអ៊ំប្រុសនិងប៉ុនន្មានដែល?

ខ៖ នៅកាលនិងខ្សត់ តែតាមពិតទៅយើងស្រលាញ់គ្នា
ហើយគេក៏រៀបចំអោយតិចតួចទៅ។ និងហើយគេមិនដឹងម៉ែឪយើងនិងនៅណាអីណីទេ។

ក៖ ចាហើយចឹងមានន័យថាខាងអ៊ំប្រុសឪពុកម្តាយគាត់និងមានចិត្តធម៏ដែល។

ខ៖ និងហើយពួកគាត់មានចិត្តធម៌ យកខ្ញុំមកអប់រំទៅ
គាយត់ថាអាណិតឃើញកំព្រាម្ដាយតាំងពីបែកពីអាពពតមកចឹងណា
សសាត់សសែអីចេងមករស់នៅជាមួយគេទៅ
រួចហើយប្ដីខ្ញុំគាត់ឃើញខ្ញុំនិងក៏ស្រលាញ់ថារស់នៅជាមួយគេអាណិត
តែធម៌តាយើងរស់នៅជាមួយគេតែនេះគេប្រើយើងហាចឹងហើយណាស់
រួចទៅប្ដីខ្ញុំនិងក៏អោយម៉ែគាត់ចូលស្ដីខ្ញុំទៅ ក៏យកទៅរៀបចំការតិចតួចទៅ និងហើយ។

ក៖ ចាអ៊ំ ចឹងអ៊ំស្រីក៏មានសំណាងដែល។

ខ៖ ចាក្មួយអើយខ្ញុំនៅជាមួយខាងប្ដីនិងគេមានចិត្តធម៌
គេស្រលាញ់គេយកយើងទៅធ្វើដូចជាកូនបង្កើតរបស់គេចឹង
ខុសអីគេអប់រំយើងចឹងទៅណា។

ក៖ ចា។

ខ៖ និងហើយមិនដែលមានអីទេ បានប្ដីមកក៏ដោយប្រកបល្អទៀត
ក្របួក៏មានអីគាត់អត់គិតទេ ប្ដីខ្ញុំគាត់ចិត្តធម៌។

ក៖ ជីវិតរបស់អ៊ំសំណាងមែនទែន។ ហាហាហា។

ខ៖ ចានិងហើយសំណាង តែគ្រាន់តែថាបានជាគ្នាទៅមុខ
បានកូនមកវេទនាក្រព្រោះឪពុកឧស្សាហ៍ឈឺ ហើយកូននៅតូចៗរកធ្វើអីមិនបាន
ខ្ញុំទៅស៊ីឈ្នួលអោយគេ ទៅបេះពោត បេះសណ្ដែកអោយគេហាលយទឹកត្រឹមៗនេះ
យប់ម៉ោងដប់ម៉ោងអីនិងបានលួយទឹកមកវិញ។

ក៖ ហើយអើខ្ញុំសូមសួរអ៊ំមួយទៀតថាតើពេលដែលអ៊ំបានជួបអ៊ំប្រុសដំបូងនិង
តើមូលហេតុអីបានស្រលាញ់គ្នាជាមួយនិងអ៊ំប្រុសណា?

ខ៖ អើកាលនិងគេទៅធ្វើការនៅចំការ ហើយខ្ញុំទៅស៊ីឈ្នួលអោយគេនៅនិងដែល
ទៅបេះសណ្ដែក បេះអីអោយគេនោះ ទៅជាមួយម្ចាស់គេនិងញគាត់ឃើញ
គាត់អាណិតដូចថាខ្ញុំកាលនិងយើងវាមានចិត្តល្អអីចឹងដែលនិងណា
ហើយគេក៏អោយម៉ែគេចូលស្ដីទៅ គេឃើញយើងគេវាអាណិត គេឃើញយើងនិងវាកំព្រា។

ក៖ ចា។

ខ៖ និងហើយ។

ក៖ រួចចុះអ៊ំស្រលាញ់អ៊ំប្រុសឬទេ?

ខ៖ ហេនិយាយពីមិនស្រលាញ់មេចប្ដីហើយ ហាហាហា។

ក៖ ហាហាហាចា។ ចឹងបានអ៊ំយល់ព្រមរៀបការជាមួយគាត់ទៅ?

ខ៖ ចាកំស្បត់កំរណាស់ពីរនាក់ប្ដីប្រពន្ធ តែបានគ្នាមកចេះតែស្រលាញ់គ្នាហើយ។

ក៖ ចាចឹងជួបគ្នាដំបូងនៅកន្លែងណាដែលអ៊ំ? នៅចំការនិងមែន?

ខ៖ អត់ទេធម្មតាពេលជួបគ្នាគឺពេលដែលសំរាកហូមបាយ
មានចំការនៅជិតៗគ្នាចឹងនិងហើយ ទៅហូមបាយនៅពេលថ្ងៃនិង
ពេលកម្មករគេសំរាកឡើងមកចឹង
គេក៏ឡើងយើងក៏ឡើងហើយដល់ពេលនេះទៅគេមកនិយាយចឹង
ដូចជាមកនិយាយដឹដងយើង គេស្រលាញ់យើងតែយើងមិនដឹងទេណា
តែមនុស្សប្រុសស្រលាញ់យើងគេចេះតែនិយាយពីលិចពីកើតអោយយើងអីចឹងណា
តែយើងមិនបានដឹង ដល់តែយូៗទៅបានម្ដាយចិញ្ចឹមនិងគេមកប្រាប់ថា មានគេស្រលាញ់។

ក៖ ចា។

ខ៖ និងហើយគាត់សួរយើងចឹងសិនណា
ដល់នេះទៅយើងក៏យកគេទៅអោយតែគេចេះស្រលាញ់យើងថែរក្សារយើង
យើងមិនស្រលាញ់គេ យើងពឹងទៅលើគេ អានិងវាចឹងអែង។

ក៖ ចាអរគុណអ៊ំ ហាហាហា។ ហើយអើខ្ញុំចង់សួរអ៊ំទៀតថា
អ៊ំចេះនិយាយនិងអានភាសារខ្មែរបានល្អទេអ៊ំ?

ខ៖ អត់ទេកូនអើយ ហាហាហា អ៊ំមិនសូវចេះអក្សរទេ។

ក៖ ចា។

ខ៖ អត់សូវចេះអក្សរទេកូនអើយចឹងបានថាអ្វីៗមក ធ្វើអ្វីតែមួយភ្លែតភ្លេចអស់
ហើយយើងមានវិប័ទអីនៅក្នុងខ្លួនសព្វគ្រប់បែបយ៉ាងទាំងអស់
ហើយចេះតែភ្លេចភ្លាំងអស់បែកម៉ែ បែកបងប្អូនយូមកហើយ

វាចេះតែមានអារម្មណ៍រកស៊ីអីទៅវាមិនដែលមានសល់លុយសល់កាក់អីទេ វាចេះតែជំពាក់គេៗចឹងណា វាចឹងជំពាក់គេថៅកែទើបតែស្តីអោយព្រឹកមិញនិងទេ។

ក៖ ចាហើយអើខ្ញុំចង់សួរអ៊ំទៀតថា អ៊ំចេះនិយាយភាសារអីផ្សេងក្រៅពីភាសារខ្មែរទេអ៊ំ ដូចជាភាសារថៃអីណា?

ខ៖ អរអត់ទេ អ៊ំមិនចេះទេ ហាហាហា ភាសារអីក៏អ៊ំអត់ចេះដែល។

ក៖ ចាចឹងខ្ញុំចង់សួរអ៊ំថា កាលអ៊ំនៅពីតូចៗណា អ៊ំធ្លាប់ទៅរៀនទីអីទេអ៊ំ?

ខ៖ ទៅរៀន ទៅរៀនមែនប៉ុន្តែជីវិតឪពុកម្តាយក្រណា។

ក៖ ចាកាលនិងអ៊ំធ្លាប់រៀនថ្នាក់ទីប៉ុន្មាន?

ខ៖ អរគឺថាខ្ញុំរៀនអត់ចេះទេ អក្សរអីនិងក៏ចប់តែម្តង។

ក៖ អរចា។

ខ៖ គឺអត់ចេះតែម្តង។

ក៖ ចាចឹងអើ ខ្ញុំចង់សួរអ៊ំទៀតថាតើអ៊ំមានមិត្តភិក្តដែលធំស្និទស្នាលមកជាមួយគ្នាទេអ៊ំ?

ខ៖ អើមិត្តភិក្តស្និទស្នាលគ្នាគេនៅស្រុកឯនុះ នៅកំពង់ចាមឯនុះតែអាឡូវនិងបែកគ្នា គ្នាវាងាប់បាត់ហើយ។

ក៖ អរចា។

ខ៖ និងហើយមិត្តភិក្តនិងវាមានពីរនាក់ ឈ្មោះក្រច្រៀបមួយ ឈ្មោះការច្រើបមួយ តែគ្នាងាប់ហើយ បែកគ្នាមកងាប់តែស្រលាញ់គ្នាណាស់ប្តូរប្តាច់ជីវិតហើយ តែមកបច្ចុប្បន្នឯនេះខ្ញុំមានប្តីមករស់នៅល្វាអែម មានប្តីកាលនិងមករស់នៅទីនេះនិងមានមិត្តភក្តិមួយរស់នៅជិតគ្នានេះឯង នេះមិត្តភក្តិគេកុំពង់តែសំភាស៍ដែលនេះ។

ក៖ ចា។

ខ៖ គេនិងក៏ខ្ញុំស្រលាញ់ដែល ជាមិត្តភកិក្តគ្នា។

ក៖ ចាចឹងអ៊ំស្រលាញ់គាត់មែនរាស់ថ្ងៃនិង?

ខ៖ ស្រលាញ់ បាយមួយចាន់និងស្រាមួយកែវចែកគ្នាបន្តិចម្នាក់ផឹក។

ក៖ អរចា។

ខ៖ និងអានិងស្រលាញ់ដោយស្មោះ។

ក៖ ចាចុះគាត់មានឈ្មោះអីដែលអំ?

ខ៖ ចាគាត់មានឈ្មោះថាសឿន។

គ៖ សឿននុះកំពង់តែសំភាស៍ដែលនុះ។

ខ៖ និងហើយកុំពង់តែសំភាស៍ដែលនុះ។

ក៖ ចាហាហារ ហើយ។

ខ៖ មិនចេះអក្សរដែល។

គ៖ ចេះអីសរសេរអក្សរខុសនោះ។

ក៖ ហាហាហា ចាបង
ហើយអើខ្ញុំចង់សួរអំទៀតថាចុះអំធ្លាប់ចាំរឿងអីខ្លះពីក្មេងៗណាដែលអំមានមិត្តភក្តិដែលគាត់ស្លាប់ទៅនិងណា? ដូចជាធ្លាប់រត់លេងជាមួយគ្នាអីចឹងចាំទេ?

ខ៖ រត់នេះវាមិត្តភក្តិជាមួយខ្ញុំនិង មិនសូវចាំទេកាលពីជំនាន់ទៅធ្វើការ លេងរត់លេងតែរត់លេងបិទពួនអិនិងគឺជាការធម្មតាទេក្មួយ។

ក៖ ចា។

ខ៖ លេងបិទពួនជាការធម្មតា លេងមឹក លួតអន់គាក់អី លេងបិទពួន
លេងឡើងដើមដំបែកលេងអីនិងលេងស្វារដណ្តើមទី
ចាប់គ្នាអីនិងមានតែប៉ុននិងក្មេងវាអត់មានអីប្លែកពីនិងទេ។

ក៖ ចា។

ខ៖ ចា។

ក៖ តែអំនៅចាំមែនទេអំ?

ខ៖ ចានៅលេងអន្ទាក់ លេងដេញវ៉ៃគ្នា
លេងអាលូតដើមដំបែកបន្ទរគ្នាគេហៅលេងស្វាចាប់ស្វារដេញដូចនៅលើមេឃចឹង
នៅលើមែកឈើ លេងនិងធ្លាក់អីចឹងទៅតែសប្បាយទៅ អានិងចឹងមិត្តភក្តិ។
តែពេលគាត់ស្លាប់ទៅអាណិតដែលប្តីអារកេ។

ក៖ អរប្តីគាត់ជាអ្នកសំលាប់គាត់?

ខ៖ និងហើយប្តីជាអ្នកសំលាប់ ធ្វើឃាត។

ក៖ មេចចឹងអំ?

ខ៖ អើគេខឹងវានិងផឹកស្រាពេក
និងហើយផឹកពេកដល់តែដឹងថាខ្ញុំរស់នៅនិងអីនិងគេមកលេងហើយ
ថាងៃមកលេងអាញមក ងៃយកលុយអោយអាញចាយផង អាញផឹក
ហើយខ្ញុំថាអើងៃគិតតែពីផឹកនិងទៅងៃ
អាញឯនេះប្រឹងរកលុយទិញអង្ករអោយកូនស៊ីមិនបានងៃគិតតែពីផឹក
រួចវាថាឃីអាញពិបាកចិត្តអញមិនទៅផឹក។ ហើយផឹកនិងដល់តែប្តីនិយាយមិនស្តាប់
ប្តីមកពីឡើងត្នោតវិញ ខឹងបាយក៏មិនទាន់ឆ្អិន ស្អីៗខោអាវកូនអីមិនកក់
តែលៃស្រវឹងខ្ពត់ពេញតែផ្ទះ ដល់ហើយគេពីបាកចិត្តគេ
ក៏ដកយកកំបិតអារត្នោតនិងវាស់ករ វាស់ករងាប់មួយរំពេកហើយឈាមដូចប្រកាច់មាន់ចឹង
គ្មានអ្នកណាដឹងទេទល់តែកូនស្រែកថា ហៅយាយៗជួយផង ប៉ាអារកម៉ែខ្ញុំ
ហើយអត់មានអ្នកណាជឿ រួចក៏នាំគ្នាភ្ញើលទាំងខ្ញុំអី ទៅមើលអារកមែន
ហើយប្តីនិងរត់គេចាប់ រត់ទៅបាត់ហើយ រត់បាត់ទល់តែសព្វថ្ងៃ
ហើយអាឡូវនិងអត់ដឹងថានៅណាអីឯនីទេ។

ក៖ គាត់ចិត្តដាច់ណាអំណា។

ខ៖ ចារួចកូនអោយអាយ៉ាវ កូនប្អូនប្រាំនាក់ អារកប្រពន្ធសុខចិត្តរត់ចោល
ខឹងប្រពន្ធផឹកស្រា អានិងវាចឹងនែក ងាប់ចោលពួកម៉ាក់ខ្ញុំមួយនិង។
ហើយពួកម៉ាក់ខ្ញុំមួយទៀតនិងនៅលើប្អូនថ្លៃខ្ញុំ
ពួកម៉ាក់ខ្ញុំនិងប្អូនប្រុសថ្លៃខ្ញុំនិងគេឃើញគេអាណិត
គេស្រលាញ់ទៅយកទៅជាអនាគត់ទៅវាចឹង តែអាឡូវនិងងាប់ដែល សុទ្ធតែក្រអត់និង។

កៈ ចា។

ខៈ ចឹងឯងក្មួយអើយ គ្មានអីទេ។

កៈ ចាអ៎ំ អរគុណអ៎ំ។ ចឹងអ៎ំខ្ញុំចង់សួរអ៎ំទៀតថា
អើតាំងពីក្មេងរហូតមកដល់អាឡូវនិងណាតើអ៎ំធ្លាប់ធ្វើការនៅវាលស្រែទេអ៎ំ?

ខៈ ធ្វើការអរ ធ្វើការនៅវាលស្រែ ទៅធ្វើការស៊ីឈ្នួលបោកស្មៅគេផង
យកអាស្មៅក្នុងស្រែនិងផង ទៅស៊ីឈ្នួលស្ទូងអោយគេផង តាំងពីមិនទាន់ចេះស្ទង់
ហេតុតែជីវិតក្រអត់ណាស់ ម្ដាយកាត់ឈើ ចេះតែទៅនិងគេ
គេថាមកៗហ៎ងអើយទៅម៉ាក់អញជួយ ជួយខ្ទប់មុខអោយឯ៎ង យកតែពីរបីត្រណោតអីទៅ
ទៅស៊ីឈ្នួលគេជាមួយចាស់អីនិងគេទៅចេះតែទៅនិងគេហើយ
ទៅធ្វើបោកប៉ាក់ជាមួយគេនិងកំសត់ណាស់ ទៅស៊ីឈ្នួលបេះនេះអោយគេ
ថាអោយតែគេប្រើអណាស់។

កៈ ចា។

ខៈ និងហើយ។

កៈ ចាចុះអ៎ំធ្លាប់ធ្វើការនៅវាសស្រែដែលម៉ែនទេអ៎ំ?

ខៈ ធ្វើខ្ញុំធ្លប់ធ្វើ តែធ្វើជួលគេទេអត់មានដីខ្លួនឯងទេ ធ្វើអោយគេជួលគេ
ធ្វើពេលធ្វើចំការអោយគេនិងពេលខ្ញុំមានប្ដីហើយ តែយកកូនយកអីនិងមកនៅល្វាអែម
ហើយពេលទៅធ្វើនិងកូនឈឺកូនអីនិងដាក់យកទៅ
ពេលឡើងមកវិញស្រូវបានប៉ុន្មានគេយកអស់អាលីងគ្មានសល់គ្មានអីទេ
ដល់ហើយអង្គុយយំពីរនាក់ប្ដីប្រពន្ធនិង។
ដល់ហើយប្ដីថាអើយឯងអើយមិនបាច់គិតច្រើនអីទេធ្វើមេចជីវិតយើង យើងប្រឹងរកទៅ
ជីវិតពួកជនវង្សក្រខ្សត់ចឹង តែវាមិនងាប់ទេ
ខ្ញុំថាអើវាគ្រាន់តែកំសត់មែនតែវាអត់ស៊ីអាឡូវនិង ចឹងខ្ញុំលូឡូវខឹងប្ដី
ដូចថាប្ដីអីឈឺច្រើនមានអារមណ៍នៅក្នុងចិត្តថាខឹងតាស់
យកអញហើយមកយកប្ដីគេចិត្តធម៌មេត្តាមែន ប៉ុនន្តែប៉ះប្ដីឈឺច្រើន។

កៈ ចា។

ខ៖ ទៅរកស៊ីអីមិនបានអោយខ្លួនឯងផ្គត់ផ្គង់ស្រួលចឹងណា ឃើញតែជួបការលំបាក
ពីបាកងាកកូនៗកូននិងក៏ច្រើនទៀត
កូនច្រើនហើយពិបាកជីវភាពកាន់តែខ្វះខាត់និងទៅទៀត
ហើយប្តីនិងឈឺទៀតអានិងចឹងដ៏ហើយទៅក៏មានចិត្តខឹងចំពោះប្តីម៉ូលម៉ៅនៅក្នុងចិត្តគិតថា
ដឹងចឹងអញមិនយកទេប្តី អានិងយើងមានចិត្តមួយខឹងចំពោះគេ
តែប្តីខ្ញុំមិនដែលវៃមិនដែលដំមេចទេ
ស្រួលអាណិតឃើញចឹងប៉ុន្តែថាគ្នាមានជំងឺឈឺច្រើនមិនបានរកស៊ីអោយជិតដល់សំរាប់ផ្គត់
ផ្គង់ជីវភាពចិញ្ចឹមប្រពន្ធកូន តែឯចំពោះឯនេះតួស្រីផងប្រុសផង
តែបានគ្នាជាប្តីប្រពន្ធហើយចេះតែរស់តិចៗទៅ
បានព្រឹកខ្វះល្ងាចនិងចេះតែរស់ចែកគ្នាស៊ីទៅ។
ប៉ុន្តែខ្ញុំរអ្វៗតែមិនដែលចេប្តីពាក្យមួយមាត់ណាអោយធ្ងន់ធ្ងរទេ
គ្រាន់តែពិបាកខ្លាំងទឹកភ្នែកខ្លួនឯង ថាធ្វើមេចទេអានិងកម្មយើង។

ក៖ ចាអរគុណអំ ចឹងខ្ញុំសូមរំខានអំ សួរអំទៀតថា
តាំងពីក្មេងរហូតមកដល់អាឡូវណាតើអំធ្លាប់មានអើអីខ្លះដែលផ្លាស់ប្តូរអត់អំ?

ខ៖ តាំងពីក្មេងមកផ្លាស់ប្តូរហើយ ផ្លាស់ពី។

ក៖ ដូចជាជីវភាពអីចឹងណាអំ។

ខ៖ ជីវភាព គឺផ្លាស់ហើយតាំងពីក្មេងមកពេលនៅជាមួយម្តាយនិងពិបាកវេទនា
ដើរតួលក់ខ្លួនឯងចិញ្ចឹមប្អូនណាស់ ដល់ពេលមានគ្រួសារទៀតធូតែមួយគ្រាទេ
តែដល់ហើយខ្លួនឯងនិងពិបាកវេទនាទៀត គឺដើរតួ
តួប្រុសតួរស្រីនិងខ្លួនឯងទៀតចិញ្ចឹមកូនអោយបានកូនធំរៀនសូត្រ និងហើយពិបាកទៀត
តួរពិបាក។

ក៖ ខ្ញុំចង់សួរអំទៀតថាតើមានម្ហូបណាខ្លះដែលអំចូលចិត្តញាំជាងគេណា?

ខ៖ ក្អួយហើយចូលចិត្តញាំជាងគេគឺកញ្ចាំប្រហុក
ព្រោះអីជីវិតយើងពីមុនមកយើងចូលចិត្តប្រហុកកញ្ចាំឆៅ ស្លរចំហុយ
ស្ងោត្រកូនឆាត្រកូននិង ជីវិតយើងស្លរប្រហើរត្រីញីបង់ស្លឹកគ្រៃអីតែប៉ុននិង។
សាច់គោមួយខាំបួនពាន់អិមិនដែលហានទិញស៊ីទេ
នឹកឃើញថាមួយខាំបួនពាន់ទិញតែបន្លែរហើយនិងត្រីប្រវាហើយ ជូនណាទៅផ្ទះថៅកែនុះ

គេចៅតែយើង ពេលបុណ្យទានម្តងៗណាគេហៅអោយសំលរអោយអីឆ្ងាញ់
ខ្ញុំនេះមិនហានស៊ីទេទុកអោយកូនចៅអីនិងនាំគ្នាស៊ីទៅ
និងហើយយើងក៏ទៅនេះទៅនុះទៀតទៅព្រោះអ្នកផឹកណា
ដើផឹកនេះតិចនុះតិចទៅគេហៅ នែមកនេះ ផឹកខ្លែមនិងគេ
បើនានសំលេឆ្ងាញ់មកយកគ្រប់ទុកអោយចៅ
អោយកូននិងចែកគ្នាស៊ីទៅ។និងហើយបានរស់មួយពេលៗ។

ក៖ ហើយអឺរខ្ញុំចង់សួរអំថា តើមានល្បែងកំសាន្តអីខ្លះដែលអំចូលចិត្តលេង
តាំងពីក្មេងរហូតមកដល់អាឡូវណា? មានដូចជាលេងបោះអង្គុញ ចោលឈូកអីណាអំ?

ខ៖ ចូលចិត្ត ចូលចិត្តរាំលេង។

ក៖ ចូលចិត្តរាំលេង ហាហាហា។

ខ៖ ចូលចិត្តរាំលេង ចាហាហាហា។

ខ៖ ចូលចិត្តរាំលេងសប្បាយបោះឈូង។

ក៖ ចាចឹងអំធ្លាប់រាំ?

ខ៖ ធ្លាប់រាំ ធ្លាប់ច្រៀងលេង។

គ.   តែម្តាយខ្ញុំចូលចិត្តរាំលេងច្រើនជាង។

ក៖ ចាហាហា ចាំមើលមានកម្មវិធីអីហៅអំទៅរាំ។

ខ៖ ហាហាហា ចាមានអី កម្មវិធីអីសប្បាយរាំលេងមិត្តភក្តិខ្ញុំអីនិងក៏ចូលចិត្តដែល
ចូលចិត្តការសំបាយនិងហើយ។

ក៖ ចឹងខ្ញុំចង់សួអំទៀតថានៅក្នុងគ្រួសារអំកូនចៅសាចញាត្តិអំអីណា
មានអ្នកណាដែលគាតើចេះលេងឧបករណ៏ភ្លេងខ្មែរឬក៏ភ្លេងសម័យអីទេអំ?

ខ៖ អរឪពុក កូនខ្ញុំអីនិងអត់មានអ្នកណាគេចេះសោះ អត់ចេះទេ ចេះតែលក់ដូរអូនអើយ។

ក៖
ចាហើយអើខ្ញុំចង់សួរអំថាតាំងពីក្មេងរហូតមកដល់អាឡូវតើផ្ទះរបស់អំនិងមានសភាពបែប
ណាដែល ការផ្លាស់ប្តូរអីខ្លះ?

ខ៖ អរឈប់មើល ខ្ញុំនិយាយពីប្រវិត្តរបស់ខ្ញុំ
ផ្ទះៗខ្ញុំនៅឯនេះជិតផ្ទះមិត្តភក្តិសំលាញ់ខ្ញុំនៅបឹងគ្រំនិងណាមាន
តែខ្ញុំមានមែនពេលចាប់ដៃគ្នាពេលគេបែកភ្នំពេញនិងណាក្មួយ
អត់មានថាលុយយើងរកពីនាក់ប្តីប្រពន្ធនិងទិញសង់ផ្ទះបានអានិងខ្ញុំនិយាយកាពិត
ផ្ទះបែកពីភ្នំពេញពីរនាក់ប្តីប្រពន្ធជញ្ជូនអាជរណាឈើគ្រេស់អត់មានម្ចាស់នៅនិងណា
ខ្ញុំនិយាយការពិត ជញ្ជូនដាក់ទូកទៅយកទៅធ្វើផ្ទះសាងសង់ផ្ទះនៅ
មិនដែលបានផ្ទះល្អឯណានៅទេ
ទៅនៅដីគេខាងប្រុសនិងគេចែកទុកដីអោយមួយដុំនិងក៏នាំគ្នានៅទៅ
មិនដែលបានផ្ទះនៅស្រុកស្រាំអីគេទេ។
ដល់ពេលនេះទៅពីរនាក់ប្តីប្រពន្ធនិងចេះតែរកៗទៅគ្មាននេះទេ
ចប់តែម្តងរកយូទៅកាន់តែកំសត់ទៅៗលក់ផ្ទះលក់អីអស់ហើយគ្មានអីនៅទេ
រួចដល់ពេលនេះ
ប្អូនថ្លៃខាងប្តីនិងដូចថាសម័យអាឡូវគេត្រូវការអោយផ្តិតមេដៃយកលុយណាក្មួយ
មានដីមួយតិចធានាអោយប្អូនគេ គេរើបយកអស់អាលឹងគ្មានដីនៅទល់តែសព្វថ្ងៃ
មករស់រនៅដូចចកនិងណា។

ក៖ ចាអ៊ំ។

ខ៖ ចឹងពេលចូលឆ្នាំមានបុណ្យទានអីម្តងៗមិនដែលបានទៅស្រុកទេ
ចុះយើងអត់មានដីផ្ទះអីនៅនិងគេ មានមិត្តភក្តិអីគេមានដីមានផ្ទះអីគេចេះតែមកនិយាយថា
ហ៎ងអើយឯងមិនបាច់គិតអីច្រើនទេមកលេងដេកផ្ទះអញអោយសប្បាយចិត្តទៅ
តែខ្ញុំអត់ទេអត់ទៅទេចូលឆ្នាំក៏នៅលក់នៅនិង
មិនចូលឆ្នាំក៏នៅនិងគ្រាំទ្រតាំងកូនទាំងចៅមួយពូជ មួយអំបូរទាំងកូនទាំងចៅ
អត់មានដែលបានទៅណានិងគេទេដីខ្ញុំនិងគេយកអស់ហើយគ្មានទេ
សព្វថ្ងៃនិងមានតែដីនៅទីនេះទេតែរស់នៅជាមួយគេហើយជួលដីគេនិង។

ក៖ ចាចឹងខ្ញុំចង់សួរអំទៀតថា តើអំធ្លាប់ជួលជុលនិងសាងសង់ផ្ទះខ្លួនឯងទេអំ?

ខ៖ អត់ផងគឺអត់មានផ្ទះផង។

ក៖ អត់ដែលទេ?

ខ៖ អត់ម៉ង អត់តែម្តង គឺអត់មានផ្ទះអត់មានដីគឺទទេស្អាត រស់ដូចចកមករស់នៅនិងគេ ហើយមើលគេទៅថាគេមានដីជួលយើងទៅលក់ដូរអោយគេនិងណា មករស់នៅទីនេះជិត ដប់មួយម្ភៃឆ្នាំហើយមករស់នៅជាមួយថៅកែនិង ចេះតែនៅៗទៅជួលដីគេនិងនៅ ផ្ទះដប់ម៉ឺនថ្លៃដីថ្លៃផ្ទះអី ហើយថ្លៃទឹកថ្លៃភ្លើងផ្សេងទៅ យើងយកមុខរបបគេនិងលក់ទៅអានិងចឹង តែបើអោយខ្ញុំត្រលប់ទៅស្រុកវិញអត់មានទេ អត់មានផ្ទះមានដីអីនៅនិងគេទេ អត់មានសោះតែម្តង បើមិនជឿទេសួរតែញាតិសន្តាជិតនិងទៅថាខ្ញុំមិនដែលមានដីអីនៅនិងគេទេ រស់នៅវេទនាតែម្តង។

ក៖ ចាចុះអើខ្ញុំចង់សួរអ៊ំស្រីមួយទៀតថា តើមានជំនាញអ្វីខ្លះដែលឪពុកម្តាយរបស់អ៊ំបានបន្តរវែនបន្សល់ទុកអោយអ៊ំណាដូចជា ជំនាញកូរស្ករវៃរល្លឹប្ញក៏អីចឹងណាអ៊ំ?

ខ៖ ខាងម៉ែខ្ញុំនិងគាត់មានជំនាញអី គឺគាត់មានរបបដូចថាមុខរបបរកស៊ីរបស់គាត់គឺអត់មានអីទេគាត់ធ្វើតែស្រែចំការរបស់គាត់ និង បើជំនាញអីក៏ថាអត់មានទេទុកអោយកូនតទៅទៀតអីអត់។ មានតែធ្វើចំការតែមួយមុខគត់ ខ្ញុំដឹងក្តីកាលណាគឺធ្វើចំការដាំអំពៅ ដាំក្រចៅអោយគេណា នៅកំពង់ចាមច្រើនតែធ្វើចំការថ្នីនិងក្រចៅអីនិង របបនិងដាំអំពៅ។

ក៖ ចាក្រចៅនិងអីគេដែលអ៊ំ?

ខ៖ ក្រចៅថ្មីនិងគេកូត គេកាប់ទៅយកមកប្រទុំពីរបីរថ្ងៃនិងអោយវាទុំទន់ទៅគេកាប់សកទៅមាន អាកំបិតដូចគេកាត់អំពៅចែក ហើយគេសង្កាត់គេតាញបូត បូតយកតែអាសក អាក្រចៅគេធ្វើបាវ។

ក៖ ចាគេយកទៅធ្វើអីគេអ៊ំ ធ្វើបាវ?

ខ៖ ចាអានិងគេធ្វើបាវ កាលពីដើមគេធ្វើបាវឈ្នួតគេយកទៅដាក់សណ្តែកដីអីនិង ល្ងរអីនិង និងគេធ្វើអានិង ចាជំនាញខាងដាំក្រចៅនិង។

ក៖ ចាចឹងអើខ្ញុំសូមសួរអ៊ំទៀតថា អើតើអ៊ំអាចប្រាប់ខ្ញុំពីពេលណាខ្លះដែលអ៊ំលំបាកជាងគេនៅក្នុងជីវិតរបស់អ៊ំណាអ៊ំ?

ខ៖ ពីបាកពេលចាប់តាំងពីរមានគ្រួសារមករហូត
ចារស់នៅជាមួយម្ដាយនិងក៏ពិបាកដែល។

ក៖ ចាអំ។

ខ៖ តែដល់ពេលមានប្ដីមក ចាប់តាំងពីពេលបែកអាពតមកគឺចាប់ពីបាកហើយណា
មកនៅជាមួយគេនិងពិបាកហើយ
ពិបាកហើយមានគ្រួសារហើយប្ដីប៉ះប្ដីឈឺនិងរឹតតែពិបាកទៅទៀតនិង។

ក៖ ចា។

ខ៖ ចឹងបានថាវាពិបាក។

ក៖ ចឹងអំឆ្លងកាត់អាការលំបាកនិងដោយរបៀបណាដែលអំ?

ខ៖ អើពិបាកនុះពិបាក និយាយមិនចេញតែម្ដង។

ក៖ ចាចឹងបន្តប់ពីសួរអំរគ្គពីបាកហើយ សួរអំរគ្គសប្បាយម្ដង ហាហាហា។

ក៖ ចឹងអើតើអំមានបទពិសោធន៍អ្វីខ្លះដែលល្អៗនៅក្នុងជីវិតរបស់អំណា
ដែលធ្វើអោយអំសប្បាយចិត្តណា? ដូចជាអនុស្សាវរីអី?

ខ៖ អនុស្សាវរីអីមានច្រើនតែមិត្តភក្តិគេនាំដើរលេងអីចង់សប្បាយ
នាំគ្នាទៅលេងនេះលេងនុះទៅចាចូលចិត្តសប្បាយៗទៅ។

ក៖ ចា។

ខ៖ ចឹងមានសប្បាយខ្លះទុកខ្លះ វាមិនមែនថាទុករហូត
គេមើលមកយើងថាកើតទុកគេនាំទៅលេងនេះនុះទៅគេចាញសារហុញអីអោយទៅ
សប្បាយនិងគេនិងឯងអីចឹងទៅ។

ក៖ ចាពេលដែលអំសប្បាយគឺពេលដែលជួបជុំមិត្តភ្ក័ត?

ខ៖ ចាជួបមិត្តភក្តិ ជួបបងប្អូនញាតិមិត្តជិតខាងអីចឹងណាគេនាំគ្នាសប្បាយអីចឹងទៅ។

ក៖ ចាចុះពេលកូនការអីនុះអំ?

ខ៖ និងហើយពេលកូនការអីសប្បាយ ហាហាហា។

ក៖ ចាសប្បាយដែល។

ខ៖ ចាសប្បាយ។

ក៖ ចាចឹងខ្ញុំចង់សួរអ៊ំទៀតថា អើអ៊ំមានពេលណាខ្លះដែលអ៊ំដូចជានៅពីក្មេងណា តើអ៊ំធ្លាប់សង្ឃឹមចង់បានអីគេពេលដែលអ៊ំធំឡើង? មានបំណងប្រាថ្នាចង់ធ្វើអី?

ខ៖ ខ្ញុំមានបំណងប្រាថ្នាថាចែក
ពេលខ្ញុំធំឡើងកាលខ្ញុំនៅកំពង់តែរៀនសូត្រជាមួយនិងម្តាយនិងណា
ថាពេលដែលខ្ញុំធំាឡើង ថាអើយអញពេលដែលអញមានប្តីទៅមេចទេ
ប្រវិត្តពីក្មេងនិងថាពេលធំក្រមុំទៅអញចង់ធ្វើពេទ្យ និងហើយចង់បានជំនាញខាងពេទ្យ
ព្រោះដំរិះនិងវាអាចចិញ្ចឹមជិវិតយើងបានបន្តរកូនបន្តរចៅបាន។

ក៖ ចា។

ខ៖ និងហើយ រួចដល់ពេលនេះទៅមិនបានធ្វើអីសោះ
ព្រោះអក្សរយើងក៏មិនចេះអីក៏មិនចេះរួចមានជំនាញទៅធ្វើអីអាឡូវនិង។
ចង់ណាស់ចិត្តខ្ញុំចង់ធ្វើពេទ្យ តែបើអោយធ្វើគ្រូមិនសូវចង់ទេ
ពេទ្យវាហើយនិងគ្រូនិងទល់តែចេះបានអាចធ្វើពេទ្យបានដែល ព្រោះយើងអត់ចេះអី
អក្សរអករះកម្មអីនិងអត់ចេះផងនិង។

ក៖ ចា។

ខ៖ និងហើយអត់ចេះអីសសោះតែម្តងនិងក្មួយឯងគិតមើល
ចឹងបានថាវាពីបាកតែបើនៅពីក្មេងគឺចិត្តខ្ញុំចង់ចង់ម្តងពីក្មេង
ចង់ដឹងចង់ចេះតែម៉ែឪក្សត់ខ្សោយតាំងពីការបណ្តុះបណ្តាលអោយរៀនមកម៉ែឪក្រ
តិចៗគាត់ប្រើទៅម៉ែឯងចេះតែប្រើខ្ញុំចង់ខ្ញុំឈប់រៀន តិចៗឈប់រៀនចឹងខ្ញុំរៀនអត់ចេះទេ។
ម៉ែខ្ញុំថាចុះកូនឯងបានឯងណាបើម៉ែឈឺណាស់ ហើយឪពុកត្រូវទៅរកស៊ីឆ្ងាយ
ម៉ែបានអ្នកណាទីពឹងចឹងកូននេះទៅ ទៅបេះនេះនិងគេលក់ទៅកូន ទៅដកក្រអៅឈូក
បេះត្រកូននៅក្នុងបឹងទៅ គេបេះឈូកនិងគេបើក
ដូចថាគេឈប់អោយបេះគេឈប់អោយរកណា
យើងអោយគេអ្នករកអីចឹងថៅកែៗគេឈប់រកហើយ គេអោយយើងទៅរកទៅ

យើងដាក់កញ្ជេនិងទៅបេះក្រអៅឈូក ត្រកួននិងយកមកទៅធ្វើអន្លក់ បានយកទៅលក់ដល់ផ្សារចង្ហេរ បានកង់កញ្ចាស់មួយនិងជិះទៅហើយ។

ក៖ ចាចឹងអរគុណអ៊ំ ខ្ញុំសូមរំខានអ៊ំមួយសំនួរទៀតចុងក្រោយ។

ខ៖ ចា។

ក៖ ចឹងខ្ញុំចង់សួរអ៊ំថា
តើអ៊ំអាចនិយាយផ្តែផ្តាំអ្វីខ្លះប្រាប់ទៅដល់កូនចៅជំនាន់ក្រោយរបស់អ៊ំណា
អោយគាត់អាចដឹងថាមេចអីមេចចឹងណាអ៊ំ?

ខ៖ ចានេះខ្ញុំចង់ផ្តែផ្តាំថា ទៅកូនៗក្រោយ
និងក្មួយៗជំនាន់ក្រោយនិងណាថាអោយប្រឹងប្រែងអោយម៉ែនទែន អនាគត់យើងណាគឺថា
អនាគត់ប្រឹងប្រែងធ្វើអីអ្វីៗកុំរើសមុខរើសអី អោយតែថាជាជំណេះវិជ្ជា
យើងត្រូវប្រឹងរៀនសូត្រ ពេលយើងចេះទៅអ្វីធ្វើអីចូលអីនិងបានទាំងអស់។

ក៖ ចាអ៊ំ។

ខ.

អានិងចឹងកុំអោយដូចចាស់ជំនាន់មុននិងអាងតែទៅរៀនហើយនិយាយថាអញមិនអីទេឈប់មួយថ្ងៃពីរថ្ងៃក៏មិនអីដែល
ដល់ពេលជ្រុលទៅពេលទៅរៀនអត់ចេះអីអានិងជំរិះអីក៏យើងអត់មានដែល។
ចាធ្វើកិច្ចការអីទៅគឺល្ងិតសូន្យតែម្តងអត់មានចេះអីទេ។
តែផ្តាំថាក្មួយៗកូនៗសម័យអាឡូវនិងប្រឹងរៀនប្រឹងតស៊ូឡើងណាស់
ដូចជាប្រឹងរៀនសូត្រទៅ យើចង់ចូលក្រុមសិល្បៈ ចូលខាងគ្រូបង្រៀន ពេទ្យខាអ្វីៗ
ខាងអង្គារ ជំរិះចេះខាងអង្គារដើរខាងអី
យើងចេះយើងធ្វើអ្វីៗបានទាំងអស់និងហើយអោយតែយើងចេះ
តែបើយើងអត់ចេះទៅធ្វើអីក៏អត់ចេញដែល
ដូចយើងអត់មានលុយចឹងអានិងពេរនិងដើទំទឹមគ្នាក្មួយ
យើងអត់មានលុយអ្វីៗយើងធ្វើអត់ចេញទេ វាប្រៀបដូចជាយើនិងអត់ចេះអក្សរចឹង
ចង់ដូចថាយើងទៅសុំការងារអ្វីមួយ គេទទួលយកតែពេលគេសួរយើងមកវិញ
អាឡូវចេះអីណាភាសារអី ហើយចុះបើភាសារខ្មែរអត់ចេះ
អីក៏អត់ចេះអង់គ្លេសអត់ចេះដូចជាខ្ញុំចឹងណា គឺអត់ចេះអី គេយកទៅធ្វើអីមិនកើត

គេអោយជួយអ្វីក៏ជួយមិនកើតអនិងចឹងណា។
ហើយផ្ដែផ្ដាំអោយកូនៗសនម័យអាឡូវនិងណា និងជំនានើក្រោយនិងអោយនេះប្រឹងឡើង
សូម្បីតែទៅរៀនសិល្បិះ វៃឃឹម
វៃអីនិងក៏គេមើលអក្សរចំរៀងគេដេញតាមបទនិងដែល។ហើយចុះបើយើងអត់ចេះមើល
ទៅមេចទៅរួច ចាអានិងចឹងអត់នេះទេ។

កះ ចាចឹងខ្ញុំអរគុណច្រើនអំ
ហើយអរគុណអំស្រីដែលបានអោយខ្ញុំជួបនិងធ្វើការសំភាស៍ជាមួយអំអំពីការសំភាស៍នេះ។
ចឹងអរគុណអំ។

ខះ ចាមិនអីទេអំជូនពរអោយក្មួយនិងបានសេចក្ដីសុខ សេចក្ដីចំរើនទៅ។

កះ ចាអរគុណអំ។